ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ :...៦១៣.៩៤៣...ប.ស្ថ

## សេចក្តីប្រកាសព័ត៌មាន

ក្រសួងបរិស្ថានមានកិត្តិយស សូមជម្រាបជូនសាធារណជន និងប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិឱ្យបានជ្រាបថា ក្រសួងបរិស្ថាន និងផលិតកម្ម ខ្មែរ មេគង្គ (KMF) បានសហការគ្នាផលិតកម្មវិធីទូរទស្សន៍ប្រចាំសប្តាហ៍ ដែលមានចំណងជើងថា«**ថៃស្អាត បរិស្ថានស្អាត**» សម្រាប់ចាក់ផ្សាយជូនទូរទស្សនិកជនទស្សនាកម្សាន្ត សំដៅលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបរិស្ថាន។ កម្មវិធីទូរទស្សន៍នេះនឹងត្រូវចាក់ផ្សាយជាផ្លូវការ នៅលើកញ្ចក់ទូរទស្សន៍ PNN នៅរៀងរាល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង ១ ដល់ម៉ោង ២ រសៀល សម្រាប់រយៈពេល ១៣ សប្តាហ៍ ហើយការចាក់ផ្សាយលើកទី១ នឹងត្រូវធ្វើឡើងនៅរសៀលថ្ងៃ ***អាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០១៦*** ក្នុងខណៈដែលប្រជាជនកម្ពុជា និងពិភពលោកទាំងមូលកំពុងប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានអន្តរជាតិ ៥ មិថុនា ក្រោមប្រធានបទ «**ចូលរួមទាំងអស់គ្នាដើម្បីពិភពលោកស្រស់ស្អាត**»។

កម្មវិធីទូរទស្សន៍ «**ថៃស្អាត បរិស្ថានស្អាត**» ត្រូវបានផលិតឡើងដោយប្រើប្រាស់ថវិការួមគ្នារវាងក្រសួងបរិស្ថាន និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈគម្រោងគាំទ្រព្រៃឈើ និងជីវៈចម្រុះ អនុវត្តដោយអង្គការវីនរ៉ុកអន្តរជាតិ (Winrock International)។ កម្មវិធីទូរទស្សន៍នេះ មានរយៈពេល ៤៥ នាទី ដែលចែកចេញជាបីវគ្គ ដោយមានប្រធានបទផ្សេងៗគ្នាផ្តោតលើ វិស័យបរិស្ថាន ហើយកម្មវិធីនេះនឹងផ្តល់ជូនទូរទស្សនិកជននូវការកម្សាន្ត ការអប់រំ និងការអំពាវនាវដល់សាធារណជនឱ្យចូលរួមក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ ២០១៦

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង*
ឯកឧត្តម ***សៅ សុភាព*** នាយកខុទ្ទកាល័យ
និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាន
ទូរស័ព្ទ៖ ០១២ ៩៧១ ២២២
សារអេឡិចត្រូនិក៖ saosopheap@yahoo.com